00643267

E30/2

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 10 / 02 / 2011
ម៉ោង (Time/Heure): 11:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើបន្ទាន់ សុំពេលវេលាបន្ថែមដើម្បីដាក់ចម្លើយតបទៅនឹង ចម្លើយតបរបស់ សហព្រះរាជអាជ្ញាទៅនឹងសំណើជាបន្ទាន់របស់ នួន ជា សុំឲ្យចាត់តាំងអ្នកជំនាញផ្នែកសម្បទា**

---

ដាក់ដោយ៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Göran SLUITER

Annebrecht VOSSENBERG (កម្មសិក្សាការីច្បាប់)

ផ្ញើជូន៖

សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

E30/2.

០០២/១៩-០៩-២០០៧-អវតក/អជសជ

**សំណើ**

១. អនុលោមតាមវិធាន ៣៩(៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")[1] និងមាត្រា ៨.៤ នៃសេចក្ដីណែនាំ "ការដាក់ឯកសារនៅ អវតក"[2] សហមេធាវីការពារក្ដីរបស់ជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្ដី") សូមដាក់សំណើសុំពន្យារពេលដើម្បីដាក់ជូនចម្លើយតបទៅនឹង "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើជាបន្ទាន់របស់ នួន ជា សុំឱ្យចាត់តាំងអ្នកជំនាញផ្នែកសម្បទា" ("ចម្លើយតប")[3] ដែលត្រូវបានជូនដំណឹងទៅភាគីនានា នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១។ ដោយសន្មតថា អង្គជំនុំជម្រះមិនមានបំណងកំណត់ពេលវេលាសម្រាប់ការដេញដោលលើសំណើនេះនៅឡើយ មេធាវីការពារក្ដីសូមលើកឡើងថាលោកលោកស្រី ចៅក្រម នឹងទទួលបានសារៈប្រយោជន៍យ៉ាងពេញលេញពីចម្លើយតបដែលត្រូវបានពិចារណានេះ។ ដោយពិចារណាលើពេលវេលាកំណត់ជាច្រើន តាម "ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ"[4] មេធាវីការពារក្ដីនឹងមិនអាចមានពេលវេលាគ្រប់គ្រាន់ដើម្បីវិភាគលើចម្លើយតបរបស់សហព្រះរាជអាជ្ញា និងរៀបចំសារណារបស់ខ្លួនដើម្បីឆ្លើយតបវិញបានទេក្នុងពេលនេះ។ រហូតដល់ថ្ងៃពុធ ទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ទើបខ្លួនអាចធ្វើបាន។ អាស្រ័យហេតុនេះហើយ មេធាវីការពារក្ដីសូមស្នើពេលវេលាប្រាំថ្ងៃបន្ថែម (បន្ទាប់ពីថ្ងៃខាងលើ)។ ឬនិយាយម្យ៉ាងទៀតថា មេធាវីការពារក្ដីស្នើសូមដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១។

---

[1] ដោយអនុលោមតាមវិធាន ៣៩(៤)៖ ("តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនអង្គជំនុំជម្រះអាចពន្យារពេលកំណត់ដែលខ្លួនបានសម្រេច"។

[2] សេចក្ដីណែនាំ អវតក/០១/២០០៧/វ០៥។ ដោយយោងលើមាត្រា ៨.៤ " សំណើឆ្លើយតបនឹងត្រូវអនុញ្ញាតនៅក្នុងករណីតែមិនមានការស្នើសុំអោយមានការដេញដោលដោយផ្ទាល់មាត់ ហើយការឆ្លើយតបនោះ ត្រូវដាក់ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃប្រតិទិន គិតពីថ្ងៃជូណដំណឹងជាភាសាដែលភាគីបានស្នើសុំ ដែលបានចែងនៅក្នុងមាត្រា ២.២ អំពីឯកសារដែលអ្នកទាំងនោះត្រូវឆ្លើយតប។

[3] ឯកសារ E-30/1, ថ្ងៃទី៨ កុម្ភៈ ២០១១, ERN 00642927–00642933។

[4] ឯកសារ E-9, ថ្ងៃទី១៧ មករា ឆ្នាំ២០១១, ERN 00635754–00635759, កថាខណ្ឌ១ ដល់ ៤។

00643269

E30/2

០០២/១៩-០៩-២០០៧-អវតក/អជសដ

**សហមេធាវីការពារក្តី នួន ជា**

**សុន អរុណ**

Michiel PESTMAN **និង** Victor KOPPE